## Warning someone



### លេងទូរស័ព្ទតាមផ្លូវ

បញ្ញា៖ សម្បត្តិឯងឧស្សាហ៍លេងទូរស័ព្ទភ្លេចខ្លួនអ៊ំា។ ពេលឆ្លងថ្នល់អីគ្រោះថ្នាក់អ៊ំាណា។
សម្បត្តិ៖ មានទៅស្អី។ ខ្ញុំមើលផ្លូវដែរតាស។ អីចឹង ខ្ញុំទៅហើយណា ង៉ៃក្រោយជួបគ្នា។
សម្បត្តិ៖ អ៊ុះ!
បញ្ញា៖ ឃើញអត់? ទើបតែនិយាយផុតពីមាត់។ គង់តែង៉ៃណាមួយទេ សម្បត្តិឯង។

### ម្ដាយនិងកូនតូច

ម្ដាយ៖ កូនអ៊ំា លេងនៅម្ដុំៗហ្នឹងបានហើយណា កុំចេញទៅថ្នល់ ម៉ូតូឡានច្រើនអ៊ំា។
ម្ដាយ៖ នែ ម៉ោវិញ! ឮអត់? កូននេះវ៉ៃ។

### សម្ភាសន៍ការងារ

បង៖ ស្អែកសម្ភាសន៍ការងារមែន? ហើយត្រៀមនៅ?
ប្អូន៖ មានអីត្រូវត្រៀម? មិនដឹងគេសួរអីខ្លះផង។
បង៖ ត្រៀមឆ្លើយសំណួរដែលគេឧស្សាហ៍សួរទៅណា។ បើអត់ត្រៀមឆ្លើយសំណួរធម្មតាៗ
ដល់ភ័យទៅ សូម្បីសំណួរអីចឹងៗក៏ឆ្លើយអត់បានល្អដែរ។
ប្អូន៖ ដឹងហើយ។
បង៖ ហើយកុំទៅយឺត។ តែយឺតដឹងតែធ្លាក់ស្វ័យប្រវត្តិម៉ង។
ប្អូន៖ វាមិនដែល។
បង៖ ប្រាប់ឲ្យហើយទេ។ បើមិនជឿ ចាំតែមើលទៅ។

| | |
|---|---|
| បញ្ញា / សម្បត្តិ | male or female / male Cambodian name |
| ភ្លេចខ្លួន | to be distracted |
| គ្រោះថ្នាក់អ៊ំាណា | very dangerous (អ៊ំា here is the spoken form of ណាស់ = very) |
| មានទៅស្អី | [it's/it'll be] alright/fine |
| តាស | emphatic/affirmative particle |
| ទើបតែនិយាយផុតពីមាត់ | I've just told you! (lit.: the words have just left my mouth) |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| គង់តែ | certainly, surely; eventually |
| ង៉ៃ | spoken form of ថ្ងៃ = day |
| នែ | exclamation (among friends, to younger ppl) to warn or attract attention |
| កូននេះវៃ | You are so irritating! |
| ... មែន ? | ..., right? |
| ធ្លាក់ស្វ័យប្រវត្តិម៉ង | to fail automatically |
| វាមិនដែល | that’s impossible / I don’t believe that |
| ចាំតែមើលទៅ | [just] wait and see |

## Cultural notes

ប្រជាជនខ្មែរជឿលើបុណ្យបាប។ នៅពេលធ្វើល្អនឹងបានបុណ្យ ហើយនៅពេលធ្វើអាក្រក់នឹងបានបាប។ ដូច្នេះពាក្យថា “ប្រាប់យកតែបុណ្យទេ” មានន័យថា អ្វីដែលគេកំពុងនិយាយប្រាប់គឺក្នុងបំណងល្អ ជាអំពើល្អ ដូច្នេះគួរតែស្តាប់តាម ដើម្បីកុំឲ្យកើតមានកំហុសឬគ្រោះថ្នាក់។

| | |
|---|---|
| ប្រាប់យកតែបុណ្យទេ | I’m telling you for good sake |
| ក្នុងបំណងល្អ | with good intentions, well-meaning |

## Additional dialogue

សម្បត្តិ៖ បញ្ញាឯង កុំទៅហ៊ានប្រថុយចូលហ៊ុនជាមួយក្រុមហ៊ុនអត់មានអីច្បាស់លាស់អីចឹងអ៊ា។ ខ្ញុំធ្លាប់រិះត្រូវគេបោក ខ្ញុំរាងហើយ។ ប្រយ័ត្នក្រខ្លួនអត់អំពើ។

បញ្ញា៖ តែ ស្តាប់គេនិយាយទៅ ទំនងដែរតាស។

សម្បត្តិ៖ បញ្ញាឯងមិនធ្លាប់ឆ្លងកាត់ មិនទាន់ដឹងទេ។ ខ្ញុំគ្រាន់តែប្រាប់មុនទេ។ កុំឲ្យថាខ្ញុំអត់បានប្រាប់។ សម្រេចចិត្តខ្លួនឯងទៅ។

| | |
|---|---|
| ប្រថុយ | to take risk |
| ចូលហ៊ុន | to invest |
| រិះ | almost, nearly |
| ត្រូវគេបោក | [be/was] cheated [by them] |
| រាង | here: to have taken a lesson from sth. |
| ក្រខ្លួន | to become poor |
| អត់អំពើ | unnecessary, useless |
| ទំនង | credible, good, proper |
| ឆ្លងកាត់ | to have experienced sth. |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.